ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍

ចុះពិនិត្យ ពិភាក្សា និងសម្របសម្រួលការដឹកនាំឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

ថ្ងៃទី០៤-០៦ ខែមិថុនា ឆ្នាំ២០២០

នៅសាលាខេត្តប៉ៃលិន

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ កន្លងទៅនេះ ក្រុមការងារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដឹកនាំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** បានចុះពិនិត្យ ពិភាក្សា និងសម្របសម្រួលការដឹកនាំឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងខេត្តប៉ៃលិន ។ ក្រោមការរៀបចំ និងសហការរបស់សាលាខេត្ត លេខាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដែលកិច្ចប្រជុំនេះបានរៀបចំឡើងនៅសាលាខេត្តប៉ៃលិន ដោយសមាសភាពចូលរួមនៅក្នុងកិច្ចពិភាក្សានេះមាន **ឯកឧត្តម ជាន់ ចាន់ធុល** អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ឯកឧត្តមអភិបាលរងខេត្ត និងលោកអភិបាលក្រុង ស្រុក នាយករងរដ្ឋបាលខេត្ត មេបញ្ជាការរងកងរាជអាវុធហត្ថ និងស្នងការរងនគរបាលខេត្ត លោកប្រធានមន្ទីរសុខាភិបាល និងតំណាងមន្ទីរពាក់ព័ន្ធក្នុងខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងតំណាងអង្គការសង្គមស៊ីវិល សរុបប្រមាណ ២២នាក់។

១.គោលបំណងនៃកិច្ចប្រជុំ ៖

- ស្តាប់របាយការណ៍វឌ្ឍនភាពនៃការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តប៉ៃលិន ក្នុងរយៈពេល០៦ខែដើមឆ្នាំ ២០២០
- ពិនិត្យ ពិភាក្សា និងស្វែងយល់ការលំបាក និងការប្រឈមក្នុងការអនុវត្តទិសដៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយផ្តោតលើខ្លឹមសារ ៖
  - គោលនយោបាយ៧ចំណុចរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
  - សេចក្តីជូនដំណឹងលេខ២១៣ របស់រាជរដ្ឋាភិបាល
  - ការអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព" ដោយមានបញ្ជូលការងារអេដស៍
  - ការដាក់បញ្ចូលឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ/សង្កាត់ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨

២. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម តែង គន្ធី** មានមតិស្វាគមន៍ និងកោតសរសើរជូនដល់សមាជិក សមាជិកា ដែលជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត គ្រប់មន្ទីរពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដែលបានចូលរួមកិច្ចប្រជុំពិភាក្សានេះ ជាពិសេសវត្តមានរបស់**ឯកឧត្តម ជាន់ ចាន់ធុល** អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ដែលបានចូមរួមពិភាក្សាដោយផ្ទាល់ ។ ក្រោយពីបានជម្រាបជូនពីគោលបំណងនៃបេសកកម្មរួចមក ឯកឧត្តមអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រគល់តួនាទីនេះជូន ឯកឧត្តមអភិបាលរងខេត្ត ទទួលបន្ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍ខេត្តប៉ៃលិន ធ្វើរបាយការណ៍វឌ្ឍនភាពលើការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដែលបានអនុវត្តក្នុងរយៈពេល០៦ខែដើមឆ្នាំ២០២០ ដូចតទៅ៖

- **ទិដ្ឋភាពទូទៅ ៖**

  - នៅខេត្តប៉ៃលិនមានមន្ទីរពេទ្យបង្អែកចំនួន០១កន្លែង ៖
    - កន្លែងសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារ
    - កន្លែងផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយរក្សាការសម្ងាត់ និងគ្លីនិកកាមរោគ

- មណ្ឌលសុខភាពចំនួន០៦កន្លែង ៖
    - កន្លែងផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយជួសចុងម្រាមដៃដល់ស្រីមានផ្ទៃពោះ ដៃគូស្ត្រីមានផ្ទៃពោះ និងប្រជាពលរដ្ឋទូទៅ
- នៅក្នុងឆ្នាំ២០១៩ បានធ្វើតេស្តឈាមរកមេរោគអេដស៍ សរុបចំនួន៤៣២៩រូប ក្នុងនោះតេស្តវិជ្ជមាន ២៣រូប ស្មើនឹង០,៥៣% ក្នុងចំណោមអ្នកជំងឺអេដស៍សរុបចំនួន៤២២រូប (កុមារ១៧រូប)។
- នៅក្នុងឆ្នាំ២០១៩ អ្នកជំងឺដែលបានបោះបង់ការព្យាបាលមានចំនួន០៩រូប (ស្ត្រី០៣រូប) និងអ្នកជំងឺដែលបានស្លាប់ចំនួន០៤រូប (ស្ត្រី០១រូប)

– **ការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ៖**

- អង្គការRHAC ធ្វើយុទ្ធនាការអប់រំផ្សព្វផ្សាយដល់ស្ត្រីបម្រើសេវាកម្សាន្តសប្បាយ បានចំនួន៦០៣រូប ក្នុងរយៈពេល០៦ខែដើមឆ្នាំ២០២០នេះ។
- អង្គការMHSS (RHAC) ធ្វើយុទ្ធនាការអប់រំផ្សព្វផ្សាយដល់ក្រុមបុរសស្រលាញ់បុរស បានចំនួន ៤៧៦រូប។
- ក្រុមអង្គការCRSចុះស្វែងរកក្រុមអ្នកជំងឺដែលលាក់មុខឱ្យមកទទួលថ្នាំព្យាបាល(Pre ART/ART)។

– **កម្មវិធីថែទាំ ៖**

- ធ្វើតេស្តឈាមលើស្ត្រីមានផ្ទៃពោះបានចំនួន៦៤៣រូប ក្នុងនោះស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍ធៀបនឹងស្ត្រីដែលបានមកពិនិត្យលើកទី១ស្មើ១០០%ហើយលទ្ធផលតេស្តវិជ្ជមាន០រូប។
- ធ្វើតេស្តឈាមលើដៃគូស្ត្រីដែលមានផ្ទៃពោះបានចំនួន២៥១រូប ស្ត្រីមានផ្ទៃពោះធ្វើតេស្តឈាមធៀបជាមួយស្ត្រីមានផ្ទៃពោះបាន៣៩% លទ្ធផលតេស្តវិជ្ជមាន០រូប។
- ធ្វើតេស្តឈាមដោយជួសចុងម្រាមដៃលើប្រជាពលរដ្ឋទូទៅ(អតិថិជន) បានចំនួន៩៤រូប ក្នុងរយៈពេល០៦ខែដើមឆ្នាំ២០២០នេះ។
- ធ្វើតេស្តឈាមដោយជួសចុងម្រាមដៃលើប្រជាពលរដ្ឋទូទៅ(អតិថិជន)នៅVCCT ចំនួន១៣៣រូប លទ្ធផលតេស្តវិជ្ជមាន០រូប។

– **កម្មវិធីព្យាបាល ៖**

- អ្នកជំងឺសកម្មព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើកុមារ (ART) ចំនួន១៦រូប។
- អ្នកជំងឺសកម្មព្យាបាលដែលបានព្យាបាលជំងឺឱកាសនិយមលើមនុស្សពេញវ័យ (Pre ART) ចំនួន ០រូប។
- អ្នកជំងឺសកម្មព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យ (ART)ចំនួន៤០៣រូប។
- អ្នកជំងឺដែលបានបោះបង់ការព្យាបាលចំនួន០៣រូប (ស្ត្រី០៣រូប) ស្មើ ០,៧១% និងអ្នកជំងឺដែលបានស្លាប់ចំនួន០២រូប (ស្ត្រី០២រូប) ស្មើ០,៤៧% ក្នុងរយៈពេល០៦ខែដើមឆ្នាំ២០២០។

៣-បញ្ហាប្រឈម និងសំណូមពរ ÷

- ដៃគូស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តឈាមមិនបានគ្រប់គោលដៅ។
- ប្រជាពលរដ្ឋទូទៅ(អតិថិជន)ធ្វើតេស្តឈាមមិនបានគ្រប់គោលដៅ។
- អ្នកជំងឺអេដស៍ចំណាកស្រុកច្រើនទៅរកស៊ីនៅក្រៅប្រទេស ពិសេសប្រទេសថៃ។
- អ្នកជំងឺអេដស៍មានសុខភាពល្អបោះបង់ការព្យាបាល។
- អង្គការដៃគូកាត់បន្ថយថវិកាសម្រាប់ដំណើរការកម្មវិធី។
- អ្នកជំងឺអេដស៍មិនមានថវិកា ដើម្បីធ្វើដំណើរមកបើកថ្នាំ ដូច្នេះពួកគាត់បោះបង់ការព្យាបាល។

បន្ទាប់ពីបានស្តាប់របាយការណ៍រួចមក ឯកឧត្តមអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានជម្រាបជូនសមាជិកក្នុងកិច្ចប្រជុំពិភាក្សា ពីទិសដៅរបស់អាជ្ញាធរថ្នាក់ជាតិដោយសង្កត់ធ្ងន់លើការរៀបចំផែនការការងារអេដស៍ ក្នុងផែនការវិនិយោគឃុំសង្កាត់ព្រមទាំងថវិការ ដើម្បីទប់ស្កាត់ការបោះបង់ការទៅទទួលសេវា លុបបំបាត់ការមាក់ងាយ និងរើសអើង និងការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។ ការជំរុញការផ្តល់ប័ណ្ណសមធម៌ដល់អ្នករស់នៅជាមួយមេរោគអេដស៍ ជួយដល់ការផ្តល់សេវាដល់អ្នកចំណាកស្រុក ពង្រឹងការអនុវត្តការងារអេដស៍តាមគោលការណ៍ណែនាំភូមិឃុំមានសុវត្ថិភាព ដើម្បីទប់ស្កាត់ការចំលងថ្មីជាពិសេសក្នុងចំណោមក្រុមយុវជន និងក្រុមប្រឈមមុខខ្ពស់ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់តាមការណែនាំនៃសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ១២៣ ។ល។

ក្រោយពីការពិភាក្សា ស្វែងយល់ និងចូលរួមមតិពីលោកអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំសង្កាត់ និងមន្ទីរជំនាញពាក់ព័ន្ធសំខាន់ៗ **ឯកឧត្តម ជាន់ ចាន់ធុល** អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានសម្រេច និងដាក់ចេញនូវសេចក្តីណែនាំ និងវិធានការមួយចំនួនដូចតទៅ ៖

១. ត្រូវបន្ថែមការកិច្ចទទួលខុសត្រូវដាក់លាក់លើការងារអេដស៍ ដល់សមាជិក~សមាជិកា ក្រុមប្រឹក្សាឃុំសង្កាត់ ជាពិសេសអ្នកទទួលខុសត្រូវការងារស្ត្រី និងកុមារ។
២. ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវមានផែនការសកម្មភាពការងារអេដស៍ឆ្លើយតប និងដោះស្រាយតាមស្ថានភាពប្រឈមជាក់ស្តែង។
៣. អភិបាលរងទទួលបន្ទុកការងារអេដស៍ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត សាលារដ្ឋបាលខេត្ត និងមន្ទីពាក់ព័ន្ធត្រូវរៀបចំកញ្ចប់ថវិកាតាមតម្រូវការជាក់ស្តែងដើម្បីអនុវត្ត។
៤. លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត មន្ទីរសុខាភិបាល និងមន្ត្រីកម្មវិធីអេដស៍មានការកិច្ចណែនាំសម្របសម្រួលលើការរៀបចំជាបច្ចេកទេស សម្រាប់រៀបចំផែនការសកម្មភាពដែលជួយដល់ការងារប្រយុទ្ធនឹងជំងឺអេដស៍រួមនៅក្នុងខេត្ត។
៥. ឯកឧត្តមអភិបាលរងខេត្ត និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍មានការកិច្ចដឹកនាំ ចាត់ចែង និងសម្របសម្រួលដែលត្រូវរាយការណ៍ពីការវិវត្តន៍ និងការលំបាកក្នុងកិច្ចប្រជុំរួមរបស់សាលាខេត្ត។

ជាងនេះទៅទៀត ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ក៏បានសង្កត់ធ្ងន់លើការអនុវត្តសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ២១៣ ដែលបានដាក់ចេញជាយុទ្ធសាស្ត្រក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ និងប្តេជ្ញាចិត្តក្នុងការអនុវត្តឱ្យបានទទួលជោគជ័យ។

ក្រោយពីមានការសម្រេចរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ក្នុងការទម្លាក់ថវិកា ការអនុវត្តសកម្មភាពសេវាសង្គមឃុំ/សង្កាត់រួចមក ឯកឧត្តមអនុប្រធាន ក្នុងនាមជំនួសមុខឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្តែងនូវការកោតសរសើរចំពោះការតាំងចិត្តយ៉ាងមុតមាំរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងមន្ត្រីគ្រប់ជាន់ថ្នាក់ ក្នុងការអនុវត្តសកម្មភាពសមស្របតាមគោលនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាល។ ជាមួយគ្នានោះ ឯកឧត្តមអនុប្រធានក៏បានរំលឹកផងដែរ ចំពោះការអំពាវនាវរបស់ប្រមុខរាជរដ្ឋាភិបាល ដែលយើងទាំងអស់គ្នាត្រូវចូលរួមជាចរន្តជាតិមួយដើម្បីកម្ពុជាឆ្ពោះទៅបញ្ចប់អេដស៍នាឆ្នាំ ២០៣០។

កិច្ចប្រជុំបានបញ្ចប់ នៅវេលាម៉ោង០៥ និង០០នាទីរសៀល នាថ្ងៃខែឆ្នាំដដែលប្រកបដោយភាពស្និទ្ធស្នាល និងរីករាយ៕

ថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០
អ្នកធ្វើរបាយការណ៍

ណែម សុខលី

អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមវេជ្ជ. តែង គន្ធី